# ចំណាប់អារម្មណរបស់

# លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិ អង្គការវិទ្យាស្ថានបើកទូលាយ

# ក្នុងសិក្ខាសាលាស្តីពី"ការផ្សព្វផ្សាយលទ្ធផលវេទិកាពិភាក្សាអំពីស្ត្រី និងការទទួលព័ត៌មាន"

# ភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១២

---------

សូមគោរពលោកបណ្ឌិត Raymond Leos សមាជិកក្រុមប្រឹក្សាភិបាលនៃអង្គការវិទ្យាស្ថានបើកទូលាយ

សូមគោរពលោកភាព សុភា អ្នកពិគ្រោះការនៃគម្រោងអភិបាលកិច្ចមូលដ្ឋាននៃក្រសួងមហាផ្ទៃ

សូមគោរព លោកស្រី អស់លោក ដែលមានវត្តមាននាពេលនេះ

ថ្ងៃនេះអង្គការវិទ្យាស្ថានបើកទូលាយមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយដោយបានទទួល អស់លោក លោកស្រីក្នុងសិក្ខាសាលាស្តីពី"ការផ្សព្វផ្សាយលទ្ធផលវេទិកាពិភាក្សាអំពីស្ត្រី និងការទទួលព័ត៌មាន"ថ្ងៃនេះ។ សិក្ខាសាលានេះ សហការរៀបចំដោយសម្ព័ន្ធ ភាពជាតិឃុំ សង្កាត់ និងអង្គការវិទ្យាស្ថានបើកទូលាយ។ តាងនាមអ្នករៀបចំកម្មវិធី នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី អស់លោក ដែលបានឆ្លៀតពេលមមាញឹកអញ្ជើញមកចូលរួមសិក្ខាសាលាថ្ងៃនេះ។

សិក្ខាសាលា ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលនៃវេទិកាពិភាក្សាពីរលើក ពាក់ព័ន្ធនិងការចូលទៅកាន់ព័ត៌មានរបស់ស្ត្រី ជាពិសេសស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងផ្សព្វផ្សាយអំពីសារសំខាន់នៃការចូលទៅកាន់ព័ត៌មាន។

លោកស្រីអស់លោក ជាទីគោរព

ដូច លោកស្រីអស់លោក បានជ្រាបហើយថា សិទ្ធិក្នុងការចូលទៅកាន់ព័ត៌មានផ្តល់ឲ្យប្រជាពលរដ្ឋនូវសិទ្ធិស្របច្បាប់មួយក្នុងការទទួលព័ត៌មាន ពាក់ព័ន្ធសេវាសាធារណៈឬពាក់ព័ន្ធវិស័យឯកជន។ ការចូលទៅកាន់ព័ត៌មាន គឺមានសារសំខាន់ណាស់សម្រាប់អភិបាលកិច្ចតាមរបៀបប្រជាធិបតេយ្យ ការចូលរួមពីសាធារណជន ការអភិវឌ្ឍសេដ្ឋកិច្ច ការការពារសិទ្ធិមនុស្ស ការជំរុញសេរីភាពព័ត៌មាន និងតម្លាភាព។ល។

ការចូលទៅកាន់ព័ត៌មានគឺជាផ្នែកមួយនៃសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ដែលត្រូវបានទទួលស្គាល់ជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ទទួលស្គាល់ដោយសេចក្តីសម្រេចចិត្តលេខ៥៩ អនុមតិដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៤៦។ សិទ្ធិក្នុងការចូលទៅកាន់ព័ត៌មានក៏ដូចជាសិទ្ធិក្នុងការបញ្ចេញមតិយោបល់មានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាបានគាំទ្រ (Universal Declaration of Human Rights) មាត្រា១៩ "មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពមានមតិ និងសេរីភាពក្នុងការសម្តែងមតិ។ សិទ្ធិនេះរាប់ទាំងសេរីភាពក្នុងការប្រកាន់មតិ និងការសម្តែងមតិ ដោយគ្មានការជ្រៀតជ្រែក ព្រមទាំងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា តាមរយៈប្រព័ន្ធឃោសនាណាមួយក៏ដោយ និងដោយឥតគិតពីព្រំដែនអ្វីឡើយ ។"

ច្បាប់និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានការពារសិទ្ធិរបស់ប្រជាពលរដ្ឋពិសេសសិទ្ធិក្នុងការចូលទៅកាន់ព័ត៌មានក៏ដូចជាសិទ្ធិក្នុងការបញ្ចេញមតិយោបល់។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣១បានចែងថា" ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ។"

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា"ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។ "

ទោះជាយ៉ាងដូច្នេះក្តី យើងសង្កេតឃើញថា ការទទួលព័ត៌មានរបស់ប្រជាពលរដ្ឋនៅមានកម្រិតអាស្រ័យដោយការចែកចាយ និងមធ្យោបាយនៃការចែកចាយនៅមានកម្រិត និងដោយសារវប្បធម៌ចែកចាយព័ត៌មានសាធារណៈមិនទាន់មានលក្ខណៈបើកចំហនៅឡើយ។ ទោះបីជាមានការរីកចម្រើន ស្ត្រីនៅតែប្រឈមនឹងឧបសគ្គនានាដែលរារាំងដល់ការទទួលព័ត៌មានរបស់ពួកគេ។ ឧបសគ្គទាំងនេះរួមមានបទដ្ឋានវប្បធម៌ និង សង្គម កង្វះខាតឱកាសនៃការអប់រំ និង បណ្តុះបណ្តាល។ សំខាន់ជាងនេះទៀតគឺកង្វះខាតនៃការយល់ដឹងពីសិទ្ធិរបស់គាត់ក្នុងការទទួលនិងផ្សព្វផ្សាយព័ត៌មានបើប្រៀបធៀបជាមួយបុរស។ កង្វះខាតទាំងនេះបានធ្វើឲ្យស្ត្រីខ្វះខាតចំណេះដឹងផ្នែកនយោបាយ និងទំនុកចិត្តភាពជឿជាក់និងជំនាញសមស្របនៅមានកម្រិត ។

ឧបសគ្គទាំងនេះបានប៉ះពាល់ដល់ការងារប្រចាំថ្ងៃរបស់ស្ត្រី ដូចជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីដែលបំពេញការងារជាច្រើននៅក្នុងការងារសាធារណៈ។ នេះ ជាឧបសគ្គធំសម្រាប់ពួកគាត់បំពេញការងាររបស់ពួកគាត់ដែលជាមន្ត្រីទទួលបន្ទុកព័ត៌មានសាធារណៈ ឬម្ចាស់ព័ត៌មានសាធារណៈ និងគាត់ជាបុគ្គលដែលត្រូវការទទួលព័ត៌មានសាធារណៈច្រើនដើម្បីបម្រើសេវាកម្មសាធារណៈនិងអត្ថប្រយោជន៍សាធារណៈអោយបានប្រសើរឡើង។

ការចូលទៅកាន់ ព័ត៌មានបានបង្កលក្ខណងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការបញ្ចេញ និងអនុវត្តសំឡេងរបស់ខ្លួន ក៏ដូចជាការចូលរួមយ៉ាងពេញលេញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់គេ។ នៅក្នុងសម័យ ICT ស្ត្រីអាចប្រើប្រាស់ព័ត៌មានសម្រាប់ការស្វែងរកការគាំទ្រ និងបង្កើតនូវការផ្សព្វផ្សាយព័ត៌មាននៅក្នុងសហគមន៍របស់ពួកគេដូចជាយុទ្ធនាការទប់ស្កាត់អំពើហិង្សាគាក់ទងនឹងយេនឌ័រត្រូវបានលើកកម្ពស់តាមរយៈនៃការប្រើប្រាស់ICT និងតាមរយៈនៃការចូលទៅកាន់ព័ត៌មានពាក់ព័ន្ធ ជាដើម។

ការចូលទៅកាន់ព័ត៌មានបានជួយដល់សហគមន៍ដែលងាយរងគ្រោះអាចធ្វើសមាហរណកម្មចូលទៅក្នុងសង្គមបាន។ ការចូលទៅកាន់ព័ត៌មានក៏បានធ្វើឲ្យការយល់ដឹងរបស់ស្ត្រីអំពី សិទ្ធិពលរដ្ឋ និងការទទួលខុសត្រូវរបស់ពួកគេមានការកើនឡើង ក៏ដូចជាការកើនឡើងនៃការប្រមូលផ្តុំស្ត្រីដែលមានចំណេះដឹង ដែលអាចចូលរួមនៅក្នុងដំណើរការបោះឆ្នោត មានដូចជាការទៅបោះឆ្នោត និង ការឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ។ ការចូលទៅកាន់ព័ត៌មាននឹងធ្វើឲ្យមានការកើនឡើងចំនួនស្ត្រីក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យសាធារណៈ និងឯកជន។ជាងនេះទៅទៀតការចូលទៅកាន់ព័ត៌មាន ក៏ធ្វើឲ្យ

សហគមន៍អាចគ្រប់គ្រងបាននូវដំណើរការបោះឆ្នោតដើម្បីជំរុញគណនេយ្យភាព តម្លាភាព និង អភិបាលកិច្ចល្អ។

ឆ្លៀតឱកាសនេះ នាងខ្ញុំសូមថ្លែងអំណរគុណដល់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដែលតែងផ្តល់ការគាំទ្រដល់អង្គការវិទ្យាស្ថានបើកទូលាយ ដល់ស្ថាប័ននិងអង្គការសហការផ្សេងៗទៀត និង ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការចូលរួមយ៉ាងសកម្មក្នុងគម្រោងនេះតាំងពីដើមដល់ចប់អស់រយៈពេលមួយឆ្នាំកន្លងមក។ នាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ Open Society Institute និង The Swedish Program for ICT in Developing Regions (SPIDER) ចំពោះការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ ធ្វើឲ្យគម្រោងនេះកើតឡើងនិងដំណើរការដល់ចប់ដោយជោគជ័យ។

មុននិងបញ្ចប់ នាងខ្ញុំសូមជូនពរ គណអធិបតី អស់លោក លោកស្រីដែលមានវត្តមាននាពេលនេះ សូមប្រកបដោយសុខភាពបរិបូរណ៌ បញ្ញាវាងវៃ និងទទួលបានជោគជ័យក្នុងរាល់ការងារ។

សូមអរគុណ